ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

លេខ:..................អសជ/...

# របាយការណ៍សវនកម្ម
# បញ្ជាក់លើ
# សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកា
# ទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង
# ឆ្នាំ២០១៤

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
# 5, St. Duong Ngeab 3, Phoum Tekthla, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA
Tel: (855-23) 885 900 , Fax : (855-23) 885 900
E-mail: naakh@naa.gov.kh website : www.naa.gov.kh

## មាតិកា


ទំព័រ

**១. សេចក្តីផ្តើម** ១

**២. គោលបំណង និងដែនកំណត់សវនកម្ម** ១

**៣. ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤** ២

**៤. លទ្ធផលសង្ខេបនៃការធ្វើសវនកម្ម** ៣

៤.១.កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ ៤

៤.២.កិច្ចប្រតិបត្តិការថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ៧

៤.៣.ការគ្រប់គ្រងបំណុល ៧

៤.៤.ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ៧

**៥. មតិអង្គសវនករ** ៧

# របាយការណ៍របស់អគ្គសវនករ

## ១. សេចក្តីផ្តើម

អាជ្ញាធរសវនកម្មជាតិត្រូវបានបង្កើតឡើង ដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈមួយដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។

យោងតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា២២ និងមាត្រា២៣ បានចែងថា រាជរដ្ឋាភិបាលត្រូវបញ្ជូនឯកសារនៃការទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗ មកអាជ្ញាធរសវនកម្មជាតិ ដើម្បីធ្វើសវនកម្មនៅក្នុងអំឡុងពេល៩ខែ បន្ទាប់ពីដំណាច់ឆ្នាំនៃការិយបរិច្ឆេទ ហើយអាជ្ញាធរសវនកម្មជាតិត្រូវធ្វើរបាយការណ៍បញ្ជាក់លើឯកសារនេះ ជូនទៅរដ្ឋសភា ព្រឹទ្ធសភា និងចម្លងជូនរាជរដ្ឋាភិបាល ដើម្បីជ្រាបជារបាយការណ៍។

រាជរដ្ឋាភិបាល បានបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ មកអាជ្ញាធរសវនកម្មជាតិ ដើម្បីធ្វើសវនកម្មនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥។ អាជ្ញាធរសវនកម្មជាតិធ្វើរបាយការណ៍បញ្ជាក់លើសេចក្តីព្រាងច្បាប់នេះ ដោយលើកឡើងដោយសង្ខេបនូវលទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ និងមតិរបស់អាជ្ញាធរសវនកម្មជាតិលើសេចក្តីព្រាងច្បាប់នេះ។

## ២. គោលបំណង និងដែនកំណត់សវនកម្ម

ការធ្វើសវនកម្មលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ គឺដើម្បីបញ្ជាក់ថា សេចក្តីព្រាងច្បាប់នេះមានភាពត្រឹមត្រូវ និងអាចទទួលយកបាន ហើយធ្វើរបាយការណ៍ជូនទៅរដ្ឋសភា និងព្រឹទ្ធសភា ស្របតាមមាត្រា២២ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយផ្តោតទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៤ និងឆ្នាំពាក់ព័ន្ធនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនដោយអនុលោមទៅតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះ តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិប្រតិបត្តិតាមក្រមសីលធម៌ ធ្វើផែនការ និងធ្វើសវនកម្ម ដើម្បីទទួលបានការធានាអះអាងដោយសមហេតុផលថា សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ពុំមានលក្ខណៈខុសឆ្គងជាសារវន្តទេ។

ការធ្វើសវនកម្មរួមមានការអនុវត្តនីតិវិធី ដើម្បីទទួលបាននូវភស្តុតាងសវនកម្មអំពីចំនួនទឹកប្រាក់ចំណូលចំណាយ និងការដាក់បង្ហាញនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ ការជ្រើសរើសនីតិវិធីទាំងនេះគឺអាស្រ័យលើការវិនិច្ឆ័យរបស់សវនករ ដោយរួមបញ្ចូលទាំងការវាយតម្លៃលើហានិភ័យនៃភាពខុសឆ្គងជាសារវន្តនៃសេចក្តីព្រាងច្បាប់នេះ ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង។ ក្នុងការវាយតម្លៃហានិភ័យទាំងនេះ សវនករបានពិចារណាទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលទាក់ទងទៅនឹងការរៀបចំ និងការបង្ហាញត្រឹមត្រូវនៃរបាយការណ៍ស្តីពី

ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលមានលក្ខណៈសមហេតុផលទៅតាមកាលៈទេសៈ។ ប៉ុន្តែ ការពិចារណានេះពុំមានគោលបំណងបញ្ចេញមតិទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្តនោះទេ។ ការធ្វើសវនកម្មនេះ រួមបញ្ចូលនូវការវាយតម្លៃលើភាពសមស្របនៃរបាយការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យដែលធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាការវាយតម្លៃលើការបង្ហាញជាទូទៅនៃសេចក្តីព្រាងច្បាប់នេះ។ ភស្តុតាងសវនកម្មដែលអាជ្ញាធរសវនកម្មជាតិទទួលបានមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់អគ្គសវនករ។

## ៣. ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញដោយត្រឹមត្រូវនូវសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដោយអនុលោមទៅតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលបានកំណត់ថា មានភាពចាំបាច់ក្នុងការរៀបចំសេចក្តីព្រាងច្បាប់នេះ មិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

នៅក្នុងឆ្នាំសារពើពន្ធ២០១៤ រាជរដ្ឋាភិបាលបានដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាជាធរមានដូចខាងក្រោម ៖

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨។
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ជំពូកទី ៤ និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១១១៣/០១៥ ចុះថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ២០១៣
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- អនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ[១]។

[១] មាត្រា១១៦ សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការដ្ឋត្រូវបានដាក់ជូនរដ្ឋសភាមុនដំណាច់ឆ្នាំ ។

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ត្រូវបានរៀបចំឡើង ដោយផ្អែកទៅតាមលទ្ធផលនៃកិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាអនុវត្តតាមរយៈរតនាគារជាតិ និង លទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសអនុវត្តក្រៅរតនាគារជាតិ។ អគ្គនាយកដ្ឋានរតនាគារជាតិជាគណនេយ្យករសាធារណៈ មានភារកិច្ចបូកសរុបចំណូល ចំណាយថវិកាទូទាំង ប្រទេស ដែលបានរៀបចំកិច្ចបញ្ជីកាគណនេយ្យដោយផ្អែកលើមូលដ្ឋានបង្គរ (គណនេយ្យទ្វេភាគ)។ តួលេខ ចំណូល ចំណាយថវិកាដែលបូកសរុបដោយអគ្គនាយកដ្ឋានរតនាគារជាតិ គឺជាមូលដ្ឋានសម្រាប់ការរៀបចំ សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដូចមានស្ថានភាពនៃកិច្ច ប្រតិបត្តិការថវិកាថ្នាក់ជាតិ កិច្ចប្រតិបត្តិការថវិកាថ្នាក់ក្រោមជាតិ (ឧបសម្ព័ន្ធ"ក") និងគុណភាពហិរញ្ញវត្ថុសាធារណៈ (ឧបសម្ព័ន្ធ"ខ") ភ្ជាប់មកជាមួយ។

## ៤. លទ្ធផលសង្ខេបនៃការធ្វើសវនកម្ម

ក្នុងឆ្នាំ២០១៤ រាជរដ្ឋាភិបាល បានធ្វើឱ្យសម្រេចនូវកំណើនសេដ្ឋកិច្ចកើនឡើងដល់ ៧,១% លើសពីការ ព្យាករណ៍ដែលបានរំពឹងទុក៧% ទោះបីអស្ថិរភាពនយោបាយក្នុងតំបន់មួយចំនួន ពិភពលោកកំពុង ប្រឈមនឹងបញ្ហាវិវាទភូមិសាស្ត្រ និងជម្លោះផ្នែកនយោបាយ និងសាសនា ហើយកម្ពុជាត្រូវបន្តប្រឈមនឹង បរិយាកាសមិនអំណោយផលផ្ទៃក្នុងមួយចំនួន ផលប៉ះពាល់ក្រោយទឹកជំនន់ឆ្នាំ២០១៣ ភាពរឹករវមួយរយៈ ចាប់ពីក្រោយការបោះឆ្នោតសកលឆ្នាំ២០១៣ ដែលបានអូសបន្លាយជិតដល់ពាក់កណ្តាលឆ្នាំ២០១៤ យ៉ាង ណាក៏ដោយ។ ជាលទ្ធផល ផ.ស.ស. សម្រាប់មនុស្សម្នាក់ៗបានកើនឡើងពី ១ ០៤៣ដុល្លារអាមេរិក នៅ ឆ្នាំ២០១៣ ដល់ ១ ១៣៨ដុល្លារអាមេរិក នៅឆ្នាំ២០១៤។ ទន្ទឹមនេះ អតិផរណាជាមធ្យមប្រចាំឆ្នាំរក្សាបាន ៣,៩% ដែលតាមការគ្រោងទុក គឺក្នុងរង្វង់៣,៥% និងអត្រាប្តូរប្រាក់ជាមធ្យមរក្សាបាន៤ ០៣៩រៀល ក្នុង មួយដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៤ ដែលតាមការគ្រោងទុកគឺក្នុងរង្វង់ ៤ ០៥០រៀល។ កំណើនខ្ពស់នេះ បានមកពីការរួមចំណែកពីវិស័យបីនៃសេដ្ឋកិច្ច គឺឧស្សាហកម្ម សេវាកម្ម និងកសិកម្ម។ រាជរដ្ឋាភិបាល កម្ពុជាបន្តអនុវត្តនូវកម្មវិធីនយោបាយរបស់ខ្លួនប្រកបដោយជោគជ័យ ដែលឆ្លុះបញ្ចាំងតាមរយៈការសម្រេច បាននូវគោលដៅធំៗ ក្នុងការបន្តពង្រឹងសន្តិភាព ស្ថិរភាព នយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការជំរុញលើកកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន រក្សាបាននូវស្ថិរភាពម៉ាក្រូ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងការពង្រឹងអភិបាលកិច្ច និងការកែទម្រង់ស្ថាប័នជាតិសំខាន់ៗ ការពារបាន យ៉ាងរឹងមាំនូវអធិបតេយ្យ និងបូរណភាពដែនដី រក្សាបានសុវត្ថិភាពសង្គម ការលើកកម្ពស់គុណភាពសេវា សាធារណៈ ក៏ដូចជាអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម តាមរយៈការជំរុញពិពិធកម្មសេដ្ឋកិច្ច ការកសាង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍស្ថាប័ន ការបង្កើតកាលានុវត្តភាពការងារ និងការអភិវឌ្ឍវិស័យឯកជន រួមទាំងការអភិវឌ្ឍធនធានមនុស្ស និងការបណ្តុះបណ្តាលជំនាញនានា ដែលជាសក្តិភាពនាំមកនូវចំណូលចរន្ត ថវិកាថ្នាក់ជាតិឆ្នាំ២០១៤ កើនឡើង ២៤,៤% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣ ចំណូលសារពើពន្ធ កើនឡើង ២៨,១% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣ សំដៅបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ជាលំដាប់។ ទាំងនេះបានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយឆន្ទៈនយោបាយ មោះមុត ឈ្លាសវៃ និង ភ្លឺស្វាងរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយសារតែរាជរដ្ឋាភិបាលអនុវត្តច្បាប់ហិរញ្ញវត្ថុយ៉ាងខ្ជាប់ខ្ជួនតាម អាទិភាពគោលនយោបាយ រួមមាន៖ (១)-ធានាបន្តអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បី

កំណើន ការងារ សមធម៌ និងប្រសិទ្ធភាពសំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដោយធានាបានទាំងស្រុងនូវការអនុវត្តគោលនយោបាយអាទិភាព និងវិធានការតាមវិស័យទាំងឡាយរបស់រាជរដ្ឋាភិបាលដែលត្រូវបានដាក់ចេញនៅក្នុង **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣"** (២)-ធានាបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុភមង្គលជូនប្រជាពលរដ្ឋ ព្រមទាំងធានាការពារឱ្យបានទាំងស្រុងនូវអធិបតេយ្យជាតិ និងបូរណភាពទឹកដី (៣)-ធានាបន្តសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព (៤)-ពង្រឹងភាពធន់ទល់នឹងវិបត្តិ និងបរិយាប័ន្នភាពនៃសេដ្ឋកិច្ច ព្រមទាំងចីរភាពនៃថវិកា (៥)-ធានាអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ២០១៤-២០១៦ ជាពិសេសបង្កើនការវិនិយោគលើវិស័យ អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍជនបទ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ដែលទទួលរងនូវការខូចខាតដោយទឹកជំនន់ក្នុងឆ្នាំ២០១៣ (៦)-អនុវត្តដំណាក់កាលទី១ នៃកម្មវិធីកំណែទម្រង់ប្រព័ន្ធបៀវត្សដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ តាមគោលការណ៍ដែលធានាបាននូវសង្គតិភាព សមធម៌ ផលិតភាពការងារ និងត្រូវផ្អែកលើភាពទ្រទ្រង់បាននៃថវិកាជាតិ (៧)-បន្តអនុវត្តការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីធានាយុត្តិធម៌សង្គម ព្រមទាំងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ សុចរិតភាព តម្លាភាព និងគណនេយ្យភាព (៨)-បន្តអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងពង្រឹងស្ថាប័នត្រួតពិនិត្យ ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពសេវាសាធារណៈជូនប្រជាជន និង (៩)-បន្តជំរុញអនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងការអភិវឌ្ឍជនបទ។

ប៉ុន្តែទន្ទឹមនឹងលទ្ធផលសម្រេចបានខាងលើ តាមរយៈការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដែលត្រូវខិតខំធ្វើឱ្យប្រសើរឡើងថែមទៀត ដូចខាងក្រោម៖

### ៤.១.កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

**+ កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាអនុវត្តតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ**

ចំណូល ចំណាយថវិកាអនុវត្តតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ជាទូទៅ មានឯកសារសំអាងត្រឹមត្រូវក្នុងការគ្រប់គ្រង និងការប្រើប្រាស់ថវិកា។ ប៉ុន្តែទន្ទឹមនឹងនេះ អាជ្ញាធរសវនកម្មជាតិក៏បានសង្កេតឃើញថា ក្រសួង ស្ថាប័នមួយចំនួនមិនទាន់ប្រតិបត្តិបានពេញលេញស្របតាមច្បាប់ និងបទប្បញ្ញត្តិក្នុងការគ្រប់គ្រងចំណូល ចំណាយថវិកានៅឡើយជាអាទិ៍៖

#### ៤.១.១. ការគ្រប់គ្រងចំណូលថវិកា

ក្នុងឆ្នាំ២០១៤ ចំណូលថវិកាសរុបសម្រេចបានចំនួន ១១ ០៣០ ៨៦០,៩លានរៀល ស្មើនឹង១៦,២៨% នៃផ.ស.ស. គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ៨,១% ហើយកើនឡើង ២១,៨%ធៀបនឹងការអនុវត្តឆ្នាំ២០១៣ ក្នុងនោះមាន៖

**ក. ចំណូលចរន្ត**

ចំណូលចរន្តអនុវត្តបានចំនួន ១០ ៨២៩ ៦៩៦,៦លានរៀល ស្មើនឹង១១១,៥%នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៩ ៧១២ ៦២៧,០លានរៀល ក្នុងនោះមាន៖

## ក.១. ចំណូលសារពើពន្ធ

ចំណូលសារពើពន្ធអនុវត្តបានចំនួន ៩ ៣៣៦ ៥០៧,៨លានរៀល ស្មើនឹង១១២,៨% នៃច្បាប់ហិរញ្ញវត្ថុគឺមានការកើនឡើង២៨,១% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៣ ក្នុងនោះមាន៖

- ចំណូលពន្ធដារអនុវត្តបានចំនួន៣ ៦៧២ ៥៦៦,៥លានរៀល ស្មើនឹង១០៧,១% នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន៣ ៤២៩ ៨០០,០លានរៀល។ ចំណូលអនុវត្តបាននេះនៅមានកម្រិតនៅឡើយ បើផ្អែកទៅលើសក្តានុពលនៃចំណូលពន្ធដារដែលអាចប្រមូលបាន មានន័យថា នៅមានចំណុចពុំទាន់ល្អមួយចំនួនដូចជា៖ ការដោះស្រាយបណ្តឹងតវ៉ា ការប្រមូលពន្ធលើឈ្នួលផ្ទះ និងដី ភាពយឺតយ៉ាវក្នុងការជម្រះផ្ទេរចំណូល ភាពយឺតយ៉ាវក្នុងការធ្វើសវនកម្មក្រុមហ៊ុន សហគ្រាស ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធពុំទាន់បានត្រឹមត្រូវ ក្រុមហ៊ុន សហគ្រាសពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ ក្រុមហ៊ុន សហគ្រាសមួយចំនួនពុំទាន់មានរបាយការណ៍សវនកម្មពីសវនករឯករាជ្យ ការប្រើប្រាស់វិក្កយបត្រពុំទាន់សមស្រប កង្វះខាតការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ ការពុំទាន់មកចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធរបស់ក្រុមហ៊ុនមួយចំនួន ការអនុវត្តវិធានការតឹងទារបំណុលពន្ធនៅមានកម្រិត ការប្រមូលពន្ធលើស្លាកយីហោនៅមានកម្រិត និងការបន្សល់ទុកនូវបំណុលពន្ធដារត្រូវទារជាច្រើន។
- ចំណូលពន្ធគយអនុវត្តបានចំនួន៥ ៤២៤ ២៣៥,០លានរៀល ស្មើនឹង១១៧,១% នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន៤ ៦៣៣ ៥០០,០លានរៀល។ ចំណូលអនុវត្តបាននេះនៅមានកម្រិតនៅឡើយ បើផ្អែកទៅលើសក្តានុពលនៃចំណូលពន្ធគយដែលអាចប្រមូលបានមួយចំនួនទៀត ដូចជា៖ ការរក្សាសាច់ប្រាក់សល់ក្នុងបេឡាចុងឆ្នាំ២០១៤ ការកំណត់តម្លៃគិតពន្ធលើទំនិញនាំចូលមិនត្រឹមត្រូវ កង្វះខាតក្នុងការតាមដានការប្រើប្រាស់ទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធ ការរក្សាសាច់ប្រាក់ក្នុងបេឡាលើសកម្រិតកំណត់ និងការបន្សល់ទុកនូវបំណុលពន្ធគយត្រូវទារជាច្រើន។
- ចំណូលសារពើពន្ធផ្សេងៗអនុវត្តបានចំនួន២៣៩ ៧០៦,៣លានរៀល ស្មើនឹង ៩៧,៧% នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន២៤៥ ៣២១,២លានរៀល។

## ក.២. ចំណូលមិនមែនសារពើពន្ធ

ចំណូលមិនមែនសារពើពន្ធអនុវត្តបានចំនួន១ ៤៩៣ ១៨៨,៨ លានរៀលស្មើនឹង១០៦,៤%នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ៤០៤ ០០៥,៨លានរៀល។ ជាមួយនឹងលទ្ធផលដែលអនុវត្តបាននេះ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចជា ការយឺតយ៉ាវក្នុងការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍ

អចលនវត្ថុមិនបានពេញលេញ និងការបន្សល់ទុកនូវបំណុលត្រូវទារគ្មានកំណត់ពេលជាច្រើន។

**ខ. ចំណូលមូលធនក្នុងប្រទេស**

ចំណូលមូលធនក្នុងប្រទេស បានមកពីសំណងនៃការខ្ចីបន្តក្នុងប្រទេសដែលជាប្រភពហិរញ្ញប្បទានមួយសម្រាប់វិនិយោគសាធារណៈអនុវត្តបានចំនួន ១៨៣ ៩៩៦,១លានរៀល ស្មើនឹង៧៩,០%នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន២៣៣ ០០០លានរៀល ។

**គ. ចំណូលមូលនិធិទ្រទ្រង់ថវិកា**

ចំណូលមូលនិធិទ្រទ្រង់ថវិកាបានមកពីឧបត្ថម្ភកធនវិនិយោគ និងការខ្ចី និងបំណុលប្រហាក់ប្រហែលអនុវត្តបានចំនួន១៦ ៧៦៨,២លានរៀល ស្មើនឹង៦,៤% នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២៦០ ០០០លានរៀល។

**៤.១.២. ការគ្រប់គ្រងចំណាយថវិកា**

ក្នុងឆ្នាំ២០១៤ ចំណាយថវិកាសរុបអនុវត្តបានចំនួន ៩ ៨២៧ ៩៥២,១លានរៀល ស្មើនឹង៩៧,០%នៃច្បាប់ហិរញ្ញវត្ថុដែលបានអនុម័តមានចំនួន១០ ១៣៥ ៦២៧,០លានរៀល ក្នុងនោះចំណាយចរន្តអនុវត្តបានចំនួន៨ ២០៤ ៩៤១,៧លានរៀល ស្មើនឹង៩៩,២% នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន៨ ២៦៨ ៧០៣,០លានរៀល មានការកើនឡើង ១២,៧% ធៀបនឹងការអនុវត្តឆ្នាំ២០១៣ និងចំណាយមូលធនអនុវត្តបានចំនួន ១ ៦២៣ ០១០,៤លានរៀល ស្មើនឹង៨៦,៩% នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ៨៦៦ ៩២៤,០រៀល ។ នៅក្នុងការអនុវត្តចំណាយថវិកានេះមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចជា៖ ក្រុមហ៊ុនចូលរួមដេញថ្លៃសាងសង់ភ្ជាប់ប្រភេទវិញ្ញាបនបត្រចុះបញ្ជីសាងសង់មិនសមស្រប ការទូទាត់ និងការកត់ត្រាចំណាយមិនទាន់អនុលោមពេញលេញតាមគោលការណ៍ហិរញ្ញវត្ថុ ការផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់មួយចំនួន តែការបើកផ្តល់ និងទូទាត់មិនទាន់ពេលវេលា ការខកខានផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មរបស់ក្រសួងស្ថាប័នមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភាពយឺតយ៉ាវរបស់ក្រសួង ស្ថាប័នក្នុងការផ្តល់តួលេខចំណូល ចំណាយថវិកាប្រចាំឆ្នាំ។

**+ កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាអនុវត្តក្រៅរតនាគារជាតិ**

ការអនុវត្តវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ដែលបានគ្រោងសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ មានតុល្យភាពចំណូលសរុបស្មើនឹងចំណាយសរុបចំនួន ៣ ៤៦០ ០០០,០លានរៀល ក្នុងនោះ អនុវត្តបានចំនួន៤ ២៤០ ៤៧៩,៩លានរៀលស្មើនឹង១២២,៦% លើសឥណទានដែលបានអនុម័តចំនួន ៧៨០ ៤៧៩,៩លានរៀល។ តួលេខវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសជាអំណោយប្រមាណចំនួន ១ ៥៧៨ ៥៤៧,៨លានរៀល ដែលអនុវត្តក្រៅរតនាគារជាតិពុំទាន់មានឯកសារគាំទ្រគ្រប់គ្រាន់សម្រាប់ធ្វើសវនកម្មនៅឡើយ។

### ៤.២. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលថវិការបស់រាជធានី ខេត្ត អនុវត្តបានចំនួន៨១១ ៦៥៩,១៥ លានរៀល និងការអនុវត្តកិច្ចប្រតិបត្តិការចំណាយថវិការបស់រាជធានី ខេត្ត អនុវត្តបានចំនួន ៧១៦ ៩០៣,០៨ លានរៀល ដូច្នេះមានអតិរេកនៃថវិការបស់រដ្ឋបាលរាជធានី ខេត្តចំនួន៩៤ ៧៥៦,០៧ លានរៀល ហើយអតិរេកនេះបានបង់ចូលថវិកាថ្នាក់ជាតិ។ ជាមួយនឹងលទ្ធផលដែលអនុវត្តបាននេះ ក៏នៅមានចំណុចគួរឲ្យកត់សម្គាល់មួយចំនួន ដូចជាៈ ការប្រមូលពន្ធប្រថាប់ត្រា ការប្រមូលពន្ធអចលនទ្រព្យពុំទាន់អស់លទ្ធភាព ការគ្រប់គ្រងប្រមូលពន្ធតាមរបបមៅការនៅមានកម្រិត និងការសេសសល់មូលដ្ឋានអាជីវកម្មនៅក្រៅបញ្ជីអនុម័តពន្ធ។

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានចំនួន៨៩ ៧១១,៧៣ លានរៀល និងការអនុវត្តកិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានចំនួន ៨៥ ២៨៥,៧៣ លានរៀល ដូច្នេះមានអតិរេកនៃថវិការបស់រដ្ឋបាលក្រុង ស្រុកចំនួន៤ ៤២៦,០០ លានរៀល ហើយអតិរេកនេះបានកត់ត្រាចូលគណនីលទ្ធផលនៃរតនាគារជាតិ ដើម្បីយោងបន្តទៅឆ្នាំបន្ទាប់។

### ៤.៣. ការគ្រប់គ្រងបំណុល

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា បំណុលត្រូវទារបានកើនឡើង ។ អាជ្ញាធរសវនកម្មជាតិក៏បានធ្វើការកត់សម្គាល់ជារៀងរាល់ឆ្នាំ ឱ្យក្រសួង ស្ថាប័នបង្កើនប្រសិទ្ធភាពនៃការទារបំណុល ដើម្បីបន្ថយការជំពាក់បំណុល ជួយបង្កើនចំណូលថវិកាជាតិ ជាប្រយោជន៍ដល់ការអភិវឌ្ឍន៍ប្រទេសជាតិ កាត់បន្ថយហានិភ័យផ្សេងៗ ដែលអាចកើតមានជាយថាហេតុ។

### ៤.៤. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

រាជរដ្ឋាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងតែបានចេញនូវបទបញ្ជា និងសារាចរណែនាំច្រើនលើកដល់គ្រប់ក្រសួង ស្ថាប័នដែលជាអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋត្រូវរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។ នៅក្នុងឆ្នាំ២០១៤ ក្រសួង ស្ថាប័នមួយចំនួននៅតែមានភាពយឺតយ៉ាវក្នុងការធ្វើតារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋ និងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ។

## ៥. មតិអគ្គសវនករ

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ បានបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែងពុះពាររបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវស្របតាមសភាពការណ៍ជាក់ស្តែង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពរីកចម្រើន និងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត គិតទាំងការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយថវិកា ការគ្រប់គ្រងបំណុល ការធ្វើកិច្ចបញ្ជិកាគណនេយ្យ។ សមិទ្ធផលទាំងនេះ បានរួមចំណែកដល់ស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រា ៧,១% នាំមកនូវចំណូលមធ្យមសម្រាប់ប្រជាជនម្នាក់ៗក្នុងមួយឆ្នាំ នាឆ្នាំ២០១៤ កើនឡើងដល់ ១ ១៣៨ ដុល្លារអាមេរិក និងការកាត់បន្ថយភាពក្រីក្រជាលំដាប់។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អគ្គសវនករកត់សម្គាល់ឃើញថា ជាមូលដ្ឋាន សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ បានបង្ហាញនូវភាពសមស្របដែលអាច

ទទួលយកបាន លើកលែងតែការកត់ត្រាតួលេខចំណូល ចំណាយដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ (អំណោយ) ពុំទាន់មានឯកសារគាំទ្រគ្រប់គ្រាន់សម្រាប់ធ្វើសវនកម្ម។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ គួរពង្រឹងការកែលំអនូវចំណុចខ្វះខាតមួយចំនួនបន្ថែមទៀត ដែលអាជ្ញាធរសវនកម្មជាតិបានធ្វើការកត់សម្គាល់កន្លងមក។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ២០១៥

**អគ្គសវនករ**

សោម គីមសួគ៌

*ឧបសម្ព័ន្ធ-ក-*

# កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

## (ដកស្រង់ចេញពីសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤)

*ឯកតា: លានរៀល*

| កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ | ឆ្នាំ២០១៤ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | លើស(+)/ខ្វះ (-) | ភាគរយ |
| | (១) | (២) | (៣=២-១) | (៤=២/១) |
| **សរុបចំណូល= (I.១ + II.១)** | **១៣ ៦៦៥ ៦២៧,០** | **១៥ ២៧០ ៩៤០,៨** | **+១ ៦០៥ ៣១៣,៨** | **១១១,៧%** |
| **សរុបចំណាយ =(I.២ + II.២)** | **១៣ ៥៩៥ ៦២៧,០** | **១៤ ០៦៧ ៩៣២,០** | **+៤៧២ ៣០៥,០** | **១០៣,៥%** |
| **អតិរេកថវិការវាងចំណូល និងចំណាយ** | **+៧០ ០០០,០** | **+១ ២០៣ ០០៨,៨** | | |
| I. កិច្ចប្រតិបត្តិការចំណូល-ចំណាយថ្នាក់ជាតិ ដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិ | | | | |
| I.១.ចំណូលថវិកា | ១០ ២០៥ ៦២៧,០ | ១១ ០៣០ ៤៦០,៩ | +៨២៤ ៨៣៣,៩ | ១០៨,១% |
| • ចំណូលចរន្ត | ៩ ៧១២ ៦២៧,០ | ១០ ៨២៩ ៦៩៦,៦ | +១ ១១៧ ០៦៩,៦ | ១១១,៥% |
| • ចំណូលមូលធនក្នុងប្រទេស | ២៣៣ ០០០,០ | ១៨៣ ៩៩៦,១ | -៤៩ ០០៣,៩ | ៧៩,០% |
| • ចំណូលមូលនិធិទ្រទ្រង់ថវិកា | ២៦០ ០០០,០ | ១៦ ៧៦៨,២ | -២៤៣ ២៣១,៨ | ៦,៤% |
| I.២.ចំណាយថវិកា | ១០ ១៣៥ ៦២៧,០ | ៩ ៨២៧ ៤៥២,១ | -៣០៨ ១៧៤,៩ | ៩៧,០% |
| • ចំណាយចរន្ត | ៨ ២៦៨ ៧០៣,០ | ៨ ២០៤ ៤៤១,៧ | -៦៤ ២៦១,៣ | ៩៩,២% |
| • ចំណាយមូលធន | ១ ៨៦៦ ៩២៤,០ | ១ ៦២៣ ០១០,៤ | -២៤៣ ៩១៣,៦ | ៨៦,៩% |
| II.វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | | | |
| II.១.ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៤៦០ ០០០,០ | ៤ ២៤០ ៤៧៩,៩ | +៧៨០ ៤៧៩,៩ | ១២២,៦% |
| II.២.ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៤៦០ ០០០,០ | ៤ ២៤០ ៤៧៩,៩ | +៧៨០ ៤៧៩,៩ | ១២២,៦% |

# កិច្ចប្រតិបត្តិការថវិកាថ្នាក់ក្រោមជាតិ

(ដកស្រង់ចេញពីសេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤)

## *ក.កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត*

*ឯកតា: លានរៀល*

| កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋបាលរាជធានី ខេត្តឆ្នាំ២០១៤ | ឆ្នាំ២០១៤ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | លើស(+)/ខ្វះ (-) | ភាគរយ |
| | (១) | (២) | (៣=២-១) | (៤=២/១) |
| **សរុបចំណូលថវិកា** | **៦៥៦ ៨៩០,០៥** | **៨១១ ៦៥៩,១៥** | **+១៥៥ ១៦៩,១០** | **១២៣,៦%** |
| **សរុបចំណាយថវិកា** | **៦៥៦ ៨៩០,០៥** | **៧១៦ ៩០៣,០៨** | **+៦០ ៨១៣,០៣** | **១០៩,២%** |
| **អតិរេកនៃថវិកាចំណូល និងចំណាយ** | | **+៩៤ ៧៥៦,០៧** | | |
| កិច្ចប្រតិបត្តិការនៃថវិការដ្ឋបាលរាជធានី ខេត្ត | | | | |
| I.ចំណូលថវិកា | ៦៥៦ ៨៩០,០៥ | ៨១១ ៦៥៩,១៥ | +១៥៥ ១៦៩,១០ | ១២៣,៦% |
| - ចំណូលចរន្ត | ៥៧០ ៥៦៨,០០ | ៦២៦ ៣២៨,១០ | +៥៥ ៧៦០,១០ | ១០៩,៨% |
| • ចំណូលសារពើពន្ធ | ៥៤៣ ៨៦០,០០ | ៥៩៣ ០១៥,០៨ | +៤៩ ១៥៥,០៨ | ១០៩,០% |
| • ចំណូលមិនមែនសារពើពន្ធ | ២៦ ៧០៨,០០ | ៣៣ ៣១៣,០២ | +៦ ៦០៥,០២ | ១២៤,៧% |
| - ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៨៥ ៩២២,០៥ | ១៨៥ ៣៣១,០៥ | +៩៩ ៤០៩,០០ | ២១៥,៧% |
| II.ចំណាយថវិកា | ៦៥៦ ៨៩០,០៥ | ៧១៦ ៩០៣,០៨ | +៦០ ៨១៣,០៣ | ១០៩,២% |
| - ចំណាយចរន្ត | ៥២០ ៣៩៧,០០ | ៥៨៣ ០៨៩,៨៣ | +៦២ ៦៩២,៨៣ | ១១២,០% |
| - ចំណាយមូលធន | ១២០ ៨៩១,០០ | ១១៨ ១៦១,៦០ | -២ ២៧៩,៤០ | ៩៨,១% |
| - ចំណាយសង្គាត់ចំណុះរាជធានី | ១៥ ៦៥២,០៥ | ១៥ ៦៥២,០៥ | ០,០០ | ១០០,០% |

## *ខ.កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក*

*ឯកតា: លានរៀល*

| កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋបាលក្រុង ស្រុក ឆ្នាំ២០១៤ | ឆ្នាំ២០១៤ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | លើស(+)/ខ្វះ (-) | ភាគរយ |
| | (១) | (២) | (៣=២-១) | (៤=២/១) |
| **សរុបចំណូលថវិកា** | **៨៧ ៨០៣,៤៤** | **៨៩ ៧១១,៧៣** | **+១ ៩០៨,២៩** | **១០២,២%** |
| **សរុបចំណាយថវិកា** | **៨៧ ៨០៣,៤៤** | **៨៥ ២៨៥,៧៣** | **-២ ៥១៧,៧១** | **៩៧,១%** |
| **អតិរេកនៃថវិកាចំណូល និងចំណាយ** | | **+៤ ៤២៦,០០** | | |
| កិច្ចប្រតិបត្តិការនៃថវិការដ្ឋបាលក្រុង ស្រុក | | | | |
| I.ចំណូលថវិកា | ៨៧ ៨០៣,៤៤ | ៨៩ ៧១១,៧៣ | +១ ៩០៨,២៩ | ១០២,២% |
| - ចំណូលចរន្ត | ១ ២៥៨,២៨ | ៣ ៧២៣,៩៩ | +២ ៤៦៩,៧១ | ២៩៦,៩% |
| • ចំណូលមិនមែនសារពើពន្ធ | ១ ២៥៨,២៨ | ៣ ៧២៣,៩៩ | +២ ៤៦៩,៧១ | ២៩៦,៩% |
| - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៨៦ ៥៤៩,១៦ | ៨៥ ៩៨៧,៧៤ | -៥៦១,៤២ | ៩៩,៤% |
| II.ចំណាយថវិកា | ៨៧ ៨០៣,៤៤ | ៨៥ ២៨៥,៧៣ | -២ ៥១៧,៧១ | ៩៧,១% |
| - ចំណាយចរន្ត | ៦៩ ០៤៤,២៨ | ៦៦ ៥២៦,៦៥ | -២ ៥១៧,៦៣ | ៩៦,៤% |
| - ចំណាយសង្គាត់ចំណុះក្រុង | ១៨ ៧៥៩,១៦ | ១៨ ៧៥៩,០៨ | -០,០៨ | ១០០,០% |

ឧបសម្ព័ន្ធ ២

# តុល្យភាពហិរញ្ញវត្ថុសាធារណៈ

(ដកស្រង់ចេញពីសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤)

ឯកតា៖ លានរៀល

| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | ហិរញ្ញប្បទាន |
|---|---|---|
| **I- ចំណូលក្នុងប្រទេស** | **១១ ០១៣ ៦៩២,៧** | |
| I.១.ចំណូលចរន្ត | ១០ ៨២៩ ៦៩៦,៦ | |
| I.២.ចំណូលមូលធនក្នុងប្រទេស | ១៨៣ ៩៩៦,១ | |
| **II- ចំណាយថវិកា** | **១៣ ៧៥៦ ១៥៣,១** | |
| II.១.ចំណាយចរន្ត | ៨ ២០៤ ៨៤១,៧ | |
| II.២.ចំណាយមូលធន | ៥ ៥៥១ ៧១១,៤ | |
| (មិនគិតការវិលសំបំណុលបរទេស៣១១.៧៧៨,៩លានរៀលទេ) | | |
| +វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១ ៣១១ ២៣១,៥ | |
| - ដោយថវិការដ្ឋ | ១ ២២៣ ៨៦០,២ | |
| • គម្រោងវិនិយោគ | ៩៣០ ៨៤៩,៤ | |
| • បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ២៩៣ ០១០,៧ | |
| - ដោយមូលនិធិទ្រទ្រង់ថវិកា | ៨៧ ៣៧១,៣ | |
| +វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ២៤០ ៨៧៩,៩ | |
| ក.អតិរេកនៃថវិកាចរន្ត (I.១– II.១) | (+)២ ៦២៥ ២៥៤,៩ | |
| ខ.ឱនភាពនៃថវិកាទូទៅ (I – II) | (-)២ ៧៤២ ៤៦០,៤ | |
| **III- ហិរញ្ញប្បទាននៃឱនភាព** | | **(+)២ ៧៤២ ៤៦០,៤** |
| **១.ហិរញ្ញប្បទានក្រៅប្រទេស** | | **(+)៣ ៩៤៥ ៤៦៩,២** |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | (+)១៦ ៧៦៨,២ |
| • វិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេស | | (+)៤ ២៤០ ៨៧៩,៩ |
| • ការទូទាត់ការខ្ចី | | (-)៣១១ ៧៧៨,៩ |
| **២.ហិរញ្ញប្បទានក្នុងប្រទេស** | | **(-)១ ២០៣ ០០៨,៨** |
| • បញ្ញើរាជរដ្ឋាភិបាល | | (-)១ ២៧៣ ៦១១,៩ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | (+)៧០ ៦០៣,១ |